សលាកប័ត្រព័ត៌មាន ៖ កម្រងឯកសារស្តីពីករណីសិក្សា ៖ វិធានការចាំបាច់ក្នុងវិវាទដីធ្លីនៅខេត្តរតនគីរី

កាលបរិច្ឆេទ ៖ ខែកុម្ភៈ ឆ្នាំ២០១២

រូបភាពរួម ៖ ករណីសិក្សានេះជាឧទាហរណ៍បង្ហាញថាសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ត្រូវបានរំលោភបំពានជាបន្តបន្ទាប់ ដែលជាការរំលោភបំពានមួយក្នុងចំណោមការរំលោភបំពានជាច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) ហើយនេះជាការបង្ហាញនូវអវត្តមានទាំងស្រុងនៃនីតិរដ្ឋ កង្វះខាតនូវលទ្ធភាពទទួលបាននូវដំណោះស្រាយតាមប្រព័ន្ធតុលាការចំពោះការរំលោភសិទ្ធិមនុស្ស និង បញ្ហានិទណ្ឌភាពដែលរីករាលដាលនៅទូទាំងប្រទេស ដែលបានបណ្តាលឲ្យប្រជាពលរដ្ឋ និងសហគមន៍ឈានទៅរកវិធានការចុងក្រោយដែលពួកគេគ្មានជម្រើស ដើម្បីការពារសិទ្ធិរបស់ពួកគេ និងដើម្បីស្វែងរកសំណង និងដំណោះស្រាយ។

សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះបង្ហាញជារូបភាពរួមស្តីពីករណីថ្មីមួយក្នុងខេត្តរតនគីរី ដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ។ សលាកប័ត្រព័ត៌មាននេះនឹងវិភាគលើផលវិបាកនានាដែលកើតចេញពីវិវាទដីធ្លីនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះនៅតាមសហគមន៍ដាច់ស្រយាល ដែលប្រជាពលរដ្ឋប្រើវិធានការចុងក្រោយ ដើម្បីទាមទារកដំណោះស្រាយដោយសារតែអសមត្ថភាព ឬកង្វះឆន្ទៈរបស់តុលាការ ដើម្បីផ្តល់យុត្តធម៌ដល់ប្រជាពលរដ្ឋ ។ សលាកប័ត្រនេះត្រូវបានតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅប្រទេសកម្ពុជា ។

សាថតារនៃករណីសិក្សា

នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ ប្រជាពលរដ្ឋចំនួនប្រមាណ៣០០នាក់ក្នុងស្រុកលំផាត់ ខេត្តរតនគីរី បានចាប់ខ្លួនបុគ្គលិកក្រុមហ៊ុន ជីង ចុង រី កម្ពុជា ខូ អិល ធី ឌី (“ជ.ច.រ”) ម្នាក់ នាយទាហាន២នាក់ និងនគរបាល២នាក់ទុករយៈពេល២ម៉ោង ។ ប្រជាពលរដ្ឋ ដែលជាជនជាតិភាគតិចទំពូន បានប្រឆាំងនឹង ក្រុមហ៊ុន ជ.ច.រ ដែលបានឈូសឆាយដីរបស់ពួកគាត់ដើម្បីដាំដំណាំកៅស៊ូ ។ យោងតាមក្រុមហ៊ុន ជ.ច.រ ក្រុមហ៊ុននេះបានទទួលដីសម្បទានចំនួន ៩.០០០ ហិចតា ក្នុងរយៈពេល៧០ឆ្នាំ សម្រាប់ដំណាំកៅស៊ូ ។ ដូចគ្នានឹងដីសម្បទានសេដ្ឋកិច្ចដទៃទៀតជាច្រើនក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលផ្តល់ដីសម្បទានដល់ក្រុមហ៊ុន ជ.ច.រ. ដោយមិនបានពិចារណាអំពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមលើសហគមន៍នេះឡើយ ដែលនេះជាការរំលោភសិទ្ធិរបស់សហគមន៍ទាំងស្រុង ។

វិធានការចុងក្រោយ

ការចាប់ខ្លួនដែលធ្វើឡើងដោយប្រជាពលរដ្ឋមានលក្ខណៈសមហេតុផលយោងតាមមាត្រា៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង។ ក្នុងករណីដែលកើតមានក្នុងខេត្តរតនគីរី បុគ្គលទាំងនោះត្រូវបានចាប់ខ្លួននៅពេលដែលពួកគេធ្វើការឆ្ការលើដី ដែលប្រជាពលរដ្ឋអះអាងថាជាដីរបស់ពួកគាត់ ដូច្នេះអាចចាត់ទុកថាបុគ្គលទាំងនោះប្រព្រឹត្តបទល្មើស ដូចជាការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ដែលជាបទមជ្ឈិមដូចមានចែងក្នុងមាត្រា៥១០ នៃក្រមព្រហ្មទណ្ឌ។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះ មិនមែនជាបទេ្ទរហេតុខុសប្លែកពីគេនោះទេ ។ ទោះបីជាករណីចាប់ខ្លួនបុគ្គលិកក្រុមហ៊ុន និងមន្ត្រីអនុវត្តច្បាប់មិនសូវកើតមានក្នុងប្រទេសកម្ពុជា ប៉ុន្តែបច្ចុប្បន្នមានកំណើននៃប្រជាពលរដ្ឋក្នុងសហគមន៍ដែលកំពុងតែព្យាយាមដោះស្រាយបញ្ហាដោយខ្លួនឯង និងរិះរកមធ្យោបាយផ្សេងៗដើម្បីបង្ខំឲ្យមានដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ និងបញ្ឈប់ការរំលោភសិទ្ធិរបស់ពួកគេដែលជាទូទៅ គឺការរំលោភលើសិទ្ធិដីធ្លី និងសិទ្ធិក្នុងការប្រើប្រាស់ធនធានធម្មជាតិ ។ ក្នុងខែថ្មីៗនេះ ផ្លូវជាតិជាច្រើនត្រូវបានបិទ រថយន្តឈូសឆាយដីត្រូវបានឃាត់ទុក ហើយឈើខុសច្បាប់ត្រូវបានដុតបំផ្លាញ ។

នីតិរដ្ឋ និងវប្បធម៌និទណ្ឌភាព

មាត្រា៥៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) ធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរក្នុងការកាន់កាប់ដីធ្លី និងសិទ្ធិកម្មសិទ្ធិត្រូវបានការពារដោយច្បាប់ ។ មាត្រា៥ នៃច្បាប់ដីធ្លី ឆ្នាំ២០០១ (“ច្បាប់”) និងមាត្រា៥៤ នៃរដ្ឋធម្មនុញ្ញចែងថា គ្មានជនណាម្នាក់ត្រូវបានគេរឹបអូសយកដីឡើយ លុះត្រាតែក្នុងករណីដីនោះជាប់ពាក់ព័ន្ធនឹង “ផល

ប្រយោជន៍សាធារណៈ" ហើយប្រសិនបើដីរបស់ពួកគេត្រូវបានដកហូត ពួកគេត្រូវទទួលបាន "សំណងជាមុនដោយសមរម្យ និងយុត្តិធម៌" ។ យោងតាមមាត្រា២៥ នៃច្បាប់នេះ ដីដែលជនជាតិដើមភាគតិចបានរស់នៅ និងបន្តធ្វើកសិកម្មតាមបែបធម្មជាតិ គឺជាដីរបស់ពួកគាត់យោងតាមច្បាប់ស្តីពីកម្មសិទ្ធិរួមរបស់ប្រទេសកម្ពុជា ហើយពួកគាត់មានសិទ្ធិ និងត្រូវបានការពារ ដោយអនុលោមតាមច្បាប់ ។ យោងតាមមាត្រា៤ និង៥ នៃអនុក្រឹតលេខ១៤៦ ដែលជាលិខិតបំភ្លឺបកស្រាយច្បាប់បន្ទាប់បន្សំដែកស្រង់ចេញពីច្បាប់ ដីសម្បទានសេដ្ឋកិច្ចអាចត្រូវបានផ្តល់ជូនក្នុងករណីដែលដីនោះអាចលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងចៀសវាងមិនឲ្យមាន ឬកាត់បន្ថយផលប៉ះពាល់លើសង្គមឲ្យនៅត្រឹមកម្រិតអប្បបរមា និងដែលមានកិច្ចពិភាក្សាជាសាធារណៈយ៉ាងពេញលេញ ។

មាត្រា១២៨ នៃរដ្ឋធម្មនុញ្ញចែងថា *"តុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ"* ដែលនេះជាកាតព្វកិច្ចមួយដែលតុលាការខកខានមិនបានអនុវត្តតាម ។ ជាងនេះទៅទៀត មាត្រា២.៣ (ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ បានចែងថារដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការធានាថា បុគ្គលដែលត្រូវបានគេរំលោភសិទ្ធិត្រូវទទួលបានដំណោះស្រាយដ៏មានប្រសិទ្ធិភាព ដោយមិនគិតថាការរំលោភសិទ្ធិនោះត្រូវបានធ្វើឡើងដោយបុគ្គលដែលជាមន្ត្រីសាធារណៈនោះទេ ។

ជំនួសឲ្យការគោរពតាមកាតព្វកិច្ច ដែលទាមទារឲ្យមានសកម្មភាពវិជ្ជមានចំពោះការអនុវត្តកាតព្វកិច្ចនោះ រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បែរជាបន្តអនុញ្ញាតឲ្យអាជីវកម្មជាតិ និងអន្តរជាតិរំលោភសិទ្ធិប្រជាពលរដ្ឋកម្ពុជាដោយមិនមានទោសអ្វីសោះ ។ តុលាការកម្ពុជាហាក់ដូចជាកំពុងបម្រើផលប្រយោជន៍ឲ្យអាជីវកម្ម ដែលភាគច្រើនជាកម្មសិទ្ធិរបស់បុគ្គលដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយរដ្ឋាភិបាល ជាជាងបម្រើផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរទូទៅ ជាពិសេសប្រជាពលរដ្ឋមកពីសហគមន៍ក្រីក្រ និងដាច់ស្រយាល ។ ដោយមិនអាចពឹងផ្អែកលើការអនុវត្តន៍ច្បាប់ប្រឆាំងអំពើពុករលួយ និងប្រព័ន្ធតុលាការកម្ពុជា ប្រជាពលរដ្ឋកម្ពុជាបានបង្ខំចិត្តការពារសិទ្ធិ និងផលប្រយោជន៍របស់ពួកគេ ដោយបានប្រថុយនឹងការប្រើប្រាស់អំពើហិង្សា ការដាក់ទោសហើយជាងនេះទៅទៀត ដោយសារការអស់ជំនឿជាក់លើស្ថាប័នក្នុងប្រទេស និងក្នុងជួររដ្ឋាភិបាល ។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ករណីនេះបង្ហាញពីការពិតនៃបញ្ហាជាច្រើនដែលកើតមាននៅក្នុងសហគមន៍ ដូចជា ការអនុញ្ញាតឲ្យអាជីវកម្មទាញយកផលប្រយោជន៍ពីសហគមន៍ប្រជាពលរដ្ឋកម្ពុជាដោយអាជ្ញាធរកម្ពុជា កង្វះខាតដំណោះស្រាយរបស់រដ្ឋាភិបាលសម្រាប់ប្រជាពលរដ្ឋដែលត្រូវបានគេរំលោភសិទ្ធិ ហើយហាក់ដូចបានជំរុញឲ្យសហគមន៍ការពារសិទ្ធិរបស់ខ្លួននៅពេលមានការរំលោភបំពានជាបន្តបន្ទាប់ ។ និន្នាការដ៏គួរឲ្យព្រួយបារម្ភនៃភាពរឹកវរវរបស់ប្រជាពលរដ្ឋបង្ហាញពី តម្រូវការចាំបាច់ដែលទាមទារឲ្យ រដ្ឋាភិបាល ចាត់វិធានការបន្ទាន់ និងម៉ឺងម៉ាត់ក្នុងកំណែទម្រង់ការអនុវត្តន៍ច្បាប់ និងប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជា ។

ក្នុងខែកញ្ញា ឆ្នាំ២០១០ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្សកម្ពុជា សាស្ត្រាចារ្យ សុរិយា សេប៊ីឌី បានកំណត់ក្របខណ្ឌច្បាស់លាស់ក្នុងកំណែទម្រង់ក្នុងវិស័យនេះ ។ របាយការណ៍នោះបានបង្ហាញពីច្បាប់ និងវិធានការជាក់លាក់ដែលត្រូវអនុវត្ត ដើម្បីធានាថា តុលាការកម្ពុជាដំណើរការដោយឯករាជ្យ និងផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធិភាពអនុលោមតាមនីតិរដ្ឋ ។ កំណែទម្រង់នោះនឹងធ្វើឲ្យប្រជាពលរដ្ឋកម្ពុជាអាចទុកចិត្តតុលាការក្នុងការការពារសិទ្ធិរបស់ពួកគេ និងផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធិភាពក្នុងករណីដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន ។ កំណែទម្រង់នេះក៏អាចលុបបំបាត់តម្រូវការរបស់សហគមន៍ក្នុងការអនុវត្តវិធានការចុងក្រោយ ដូចហេតុការណ៍ដែលកើតឡើងក្នុងខេត្តរតនគីរី ។

ប្រសិនបើមិនមានការអនុវត្តជំហ៊ានទាំងនេះដើម្បីបង្កើតនីតិរដ្ឋ និងលុបបំបាត់និទណ្ឌភាពនោះទេ បញ្ហាទាំងនេះនឹងបន្តកើតមាន ហើយនឹងកាន់តែធ្ងន់ធ្ងរ ។ ប្រជាពលរដ្ឋកាន់តែច្រើននឹងមានគ្រោះថ្នាក់ របួស ឬជួបបញ្ហាធ្ងន់ធ្ងរជាងនេះទៅទៀត ដែលជាបច្ចុយអវិជ្ជមានដល់ប្រជាពលរដ្ឋ សង្គម និងកេរ្តិ៍ឈ្មោះរបស់កម្ពុជា ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក អ៊ូច ឡេង តាមរយៈទូរស័ព្ទ (+៨៥៥ (0) ១៦ ៧០ ៥៥ ៦៧) ឬអ៊ីម៉ែល ouchleng@cchrcambodia.org **ឬ លោក រ៉ូប៊ឺត ហ្វីនដ៍ (+៨៥៥ (0) ៧៨ ៨០ ៩៩ ៦០) ឬអ៊ីម៉ែល** robert.finch@cchrcambodia.org ។

Cambodian Center for Human Rights